# ស្ត្រីនិងក្មេងស្រីក្នុងបរិវត្តកម្មឌីជីថល

## បទពិសោធន៍និងបញ្ហាប្រឈមក្នុងការសិក្សាស្រាវជ្រាវនិងបង្ហាត់និស្សិត

## Women and Girls in Digital Transformation

### Experiences and challenges in research and students teaching

*ដោយៈ* **លោកស្រីបណ្ឌិត ព្រំ ទេវី**

*អនុប្រធានវិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម*

*រាជបណ្ឌិត្យសភាកម្ពុជា*

Email: promtevy@rac.gov.kh

## សេចក្តីផ្តើម

*ស្របគ្នានឹងបរិយាកាសនៃការប្រើប្រាស់បច្ចេកវិទ្យាកាន់តែខ្លាំងក្នុងជីវភាពរស់នៅក្នុងសង្គម សេដ្ឋកិច្ច និងនយោបាយនាពេលបច្ចុប្បន្ន ខួបទិវាអន្តរជាតិនារី លើកទី១១៣ នាឆ្នាំ២០២៤នេះ ប្រារព្ធធ្វើឡើងនៅព្រះរាជាណាចក្រកម្ពុជាក្រោមមូលបទ* ***ស្ត្រីនិងក្មេងស្រីក្នុងបរិវត្តកម្មឌីជីថល*** *។*

*យោងតាមវចនានុក្រមខ្មែរចេញផ្សាយឆ្នាំ២០២២របស់ក្រុមប្រឹក្សាជាតិភាសាខ្មែរ បរិវត្តន៍ មានន័យថា* ***ដំណើរការផ្លាស់ប្តូរឬបំប្លែងអ្វីមួយឱ្យទៅជាអ្វីមួយផ្សេងទៀត*** *ហើយ* ***ឌីជីថល*** *មានន័យថា សញ្ញាតំណាងដោយលេខ។ ចុះអ្វីទៅជាបរិវត្តកម្មឌីជីថល?* Sascha Krause et.al. *ក្នុង* Sage Journals *បានបង្ហាញថា*[1] *ចាប់តាំងពីប្រហែលជាឆ្នាំ២០០៣មក មានអត្ថបទស្រាវជ្រាវពាក់ព័ន្ធនឹងពាក្យបរិវត្តកម្មឌីជីថលមិនជាច្រើនប៉ុន្មានទេ តែចំនួននេះហក់ឡើងខ្លាំងចាប់តាំងពីឆ្នាំ២០១៤ម៉្លោះហើយការផ្តល់និយមន័យក៏មានច្រើនបែបច្រើនយ៉ាង ទៅតាមទស្សនៈរបស់អ្នកនិពន្ធម្នាក់ៗ។*

*បរិវត្តកម្មឌីជីថលគឺជានីតិវិធីនៃការប្រើប្រាស់បច្ចេកវិទ្យាដើម្បីផ្លាស់ប្តូរនិងធ្វើឱ្យប្រសើរឡើង យ៉ាងឆាប់រហ័សក្នុងមុខរបរប្រចាំថ្ងៃ។*

*ការរីករាលដាលនៃជំងឺកូវីដ១៩ចាប់តាំងពីចុងឆ្នាំ២០១៩មកដល់ពេលបច្ចុប្បន្ន បានធ្វើឱ្យបាត់បង់អាយុជីវិតមនុស្សជាច្រើននាក់*

---

[1] Sascha Krause et.al.: Digital Transformation: An Overview of the Current State of the Art of Research. In: https://journals.sagepub.com/doi/10.1177/21582440211047576, retrieved on 8th of March 2024.

ស្ថានភាពសេដ្ឋកិច្ចក៏មានការលំបាក ដោយសារគ្រប់ៗគ្នាត្រូវរក្សាគម្លាត។ បរិវត្តកម្មឌីជីថលមានយូរមកហើយ តែការទទួលយកនៅកម្ពុជាមិនសូវច្រើនប៉ុន្មានទេ លុះមានភាពចាំបាច់ដើម្បីការពារអាយុជីវិតកំលុងពេលមានរោគរាតត្បាត ការប្រើប្រាស់ក៏មានការកើនឡើងខ្លាំង។ ទោះជាហានិភ័យធ្ងន់ធ្ងរខាងលើសឹងតែកន្លងផុតទៅហើយក្តី ស្ត្រីនិងក្មេងស្រីនៅបន្តប្រើប្រាស់បច្ចេកវិទ្យាឌីជីថលមិនចាញ់បុរសនិងក្មេងប្រុសឡើយ។ តាមរយៈបទពិសោធន៍កន្លងមកក្នុងនាមជាគ្រូបង្រៀនម្នាក់ អ្នកនិពន្ធសូមលើកឡើងពីបទពិសោធន៍មួយចំនួនពាក់ព័ន្ធនឹងបរិវត្តកម្មឌីជីថលរបស់ស្ត្រីនិងក្មេងស្រីក្នុងការសិក្សាស្រាវជ្រាវនិងបង្ហាត់និស្សិត។

នគរូបនីយកម្ម គឺសំដៅទៅលើបម្លាស់ប្តូរចំនួនប្រជាជន ពីទីជនបទទៅទីប្រជុំជន ឬទីក្រុងនៅក្នុងប្រទេសនីមួយៗ ដែលជាហេតុបណ្តាលឱ្យមានរីករាលដាល ទាំងទំហំ ទ្រង់ទ្រាយ និងទីតាំងភូមិសាស្ត្រនៃតំបន់ទាំងនោះ។ដំណើរការនៃការរៀបចំ និងអភិវឌ្ឍទីក្រុងនិងទីប្រជុំជន គឺកើតឡើងដោយសារតម្រូវការនានា របស់មនុស្សដែលមានវត្តមាននៅទីនោះ ពោលគឺការបង្កើនល្បឿនលើគ្រប់វិស័យ។ គណៈកម្មការបច្ចេកសព្ទភូមិវិទ្យានៃក្រុមប្រឹក្សាជាតិភាសាខ្មែរ បានពន្យល់ថា "នគរូបនីយកម្ម គឺជាសិល្បៈ វិទ្យាសាស្ត្រ និងបច្ចេកទេសនៃការធ្វើផែនការរូបវន្តទីក្រុង ការអភិវឌ្ឍ ការអភិរក្ស ការកែលម្អនៅក្នុងទីក្រុងនិងតំបន់ជុំវិញ ព្រមទាំងតំបន់ទទួលឥទ្ធិពល ក្នុងគោលបំណងទទួលបាននូវចីរភាព តុល្យភាព សុខុមាលភាព សោភណភាព សមធម៌ និងសមាហរណកម្ម[2]។ ទោះបីជាមាន ការកំណត់ន័យដោយឡែកៗពីគ្នា រវាងប្រទេសនីមួយៗយ៉ាងណាក៏ដោយ ក៏ការធ្វើនគរូបនីយកម្ម ត្រូវបានកត់សម្គាល់ក្នុងន័យរួមមួយ គឺការរីកចម្រើនរបស់ទីក្រុង ឬទីប្រជុំជន។ ស្របតាម បរិបទសាកលភាវូបនីយកម្ម ការរៀបចំដែនដី និងនគរូបនីយកម្មនៅកម្ពុជា ជាផ្នែកចម្បងមួយនៃគោលនយោបាយដីធ្លី និងនគរូបនីយកម្ម ដែលត្រូវមានលក្ខណៈទន់ភ្លន់ និងតម្រង់ទិសគាំទ្រការអភិវឌ្ឍសេដ្ឋកិច្ចសង្គម ឱ្យមានប្រសិទ្ធភាព និងចីរភាព។ ចំណុចមូលដ្ឋានទាំងនេះ គឺជាប្រការដ៏សំខាន់សម្រាប់ប្រទេសកម្ពុជា ដែលទើបទទួលបានសុខសន្តិភាពឯកភាពជាតិ និងទឹកដីពេញបរិបូរណ៍ បន្តដោយការពង្រឹងស្មារតីបង្រួបបង្រួម សាមគ្គីភាព ការស្រឡាញ់ទឹកដី និងសង្គមកម្ពុជាទាំងមូល ដើម្បីធ្វើសមាហរណកម្មសេដ្ឋកិច្ចផ្ទៃក្នុង ការថែរក្សា

[2] ក្រុមប្រឹក្សាជាតិភាសាខ្មែរ សទ្ទានុក្រម ភូមិវិទ្យា និង ប្រវត្តិវិទ្យា ទំព័រ ២៧

និងស្រឡាញ់ទឹកដី ធនធានធម្មជាតិ វប្បធម៌ អរិយធម៌ជាតិ ដែលត្រូវបានបំផ្លិចបំផ្លាញ ដោយសារសង្គ្រាមអូសបន្លាយអស់ជាច្រើនទសវត្សរ៍កន្លងមក។

វិស័យនគរូបនីយកម្មនៅកម្ពុជា កំពុងមានសំទុះនិងវិសាលភាពធំ ដែលមិនធ្លាប់មានពីមុន។ តាមការព្យាករណ៍ នៅត្រឹមឆ្នាំ២០៣០ ប្រជាជនកម្ពុជាប្រមាណ១/៣ នឹងរស់នៅក្នុងតំបន់ទីប្រជុំជន[3]។ កត្តាប្រឈមផ្សេងៗ ក្នុងការពង្រឹងសេវាសង្គម និងហេដ្ឋារចនាសម្ព័ន្ធទីក្រុង ដើម្បីឱ្យស៊ីសង្វាក់នឹងកំណើនប្រជាជន អាចនាំឱ្យមានហានីភ័យមួយចំនួន ដូចជា ផលប៉ះពាល់បរិស្ថាន ភាពក្រីក្រ និងហានិភ័យផ្នែកសេដ្ឋកិច្ច។ ដូច្នេះ សក្តានុពលសម្រាប់អភិវឌ្ឍប្រទេសកម្ពុជា ត្រូវពឹងផ្អែកជាខ្លាំងលើការគ្រប់គ្រងទីក្រុង និងទីប្រជុំជន។ ការអភិវឌ្ឍទីក្រុង បានល្អស្របទៅតាមផែនការត្រឹមត្រូវ អាចនាំឱ្យយើងទទួលបាននូវកំណើនខ្ពស់ប្រកបដោយបរិយាបន្ន និងកាត់បន្ថយបានច្រើននូវការបញ្ចេញជាតិពុលទៅក្នុងបរិយាកាស ហើយដំណោះស្រាយ អាចចាប់ផ្តើមពីជំហ៊ានតូចៗ ដែលបុគ្គលម្នាក់ៗអាចធ្វើបាន ដើម្បីផ្លាស់ប្តូរទីក្រុង។ នគរូបនីយកម្ម មានតួនាទីវិជ្ជមាន ប្រសិនបើភាគីពាក់ព័ន្ធនានា អាចធ្វើការរួមគ្នា តាមរយៈយន្តការសម្របសម្រួលមួយ ដែលអាចបញ្ចៀសរបៀបធ្វើការដាច់ដោយឡែកពីគ្នា និងបង្កើននូវភាពស៊ីសង្វាក់គ្នានៃសកម្មភាពនានា ជាមួយនឹងដំណោះស្រាយថ្មីៗបន្ថែមទៀត។ តើនគរូបនីយកម្មនៅកម្ពុជា មានប្រវត្តិ ការវិវត្ត និងបញ្ហាប្រឈមដូចម្តេចខ្លះ?

## ១- ប្រវត្តិនគរូបនីយកម្មនៅកម្ពុជា

ឆ្លងតាមដំណើរប្រវត្តិសាស្ត្ររបស់មនុស្សភាគច្រើននៃការផ្លាស់ទីកន្លែងរស់នៅ គឺដើម្បីស្វែងរកលទ្ធភាពចិញ្ចឹមជីវិត។ ដំណើរវិវត្តដែលមានលទ្ធភាពបង្កបង្កើនផល បានរីកចម្រើនរួមជាមួយនឹងចលនាមនុស្ស កាន់តែមានកំណើនបន្តិចម្តងៗ អត្រាសមាមាត្រនៃមនុស្សរវាងតំបន់នីមួយៗ កាន់តែមានភាពខុសគ្នា។ ក្រោយបដិវត្តន៍កសិកម្មនិងឧស្សាហកម្មនៅអឺរ៉ុប នាសតវត្សទី១៨ ចំនួនប្រជាជនបានធ្វើចលនាផ្លាស់ទីយ៉ាងខ្លាំងពោលគឺផ្លាស់ទីពីជនបទមកទីក្រុងនិងទីប្រជុំជន។ លក្ខណៈបែបនេះកើតមានជាបន្តបន្ទាប់ ហើយក៏មិនសូវខុសគ្នាប៉ុន្មានដែរ សម្រាប់បណ្តាប្រទេសអភិវឌ្ឍជាច្រើនទៀតជុំវិញពិភពលោក។ ទម្រង់នៃនគរូបនីយកម្មបែបនេះ បានរីករាល

[3] របាយការណ៍ វេទិការនគរូបនីយកម្មកម្ពុជាលើកទី១ ថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០១៩ ទំព័រ ១១

ដាលយ៉ាងឆាប់រហ័សទូទាំងសាកលលោក រហូតដល់ពាក់ កណ្តាលសតវត្សទី២០ និងបានរាលដាលទៅដល់ប្រទេសកំពុងអភិវឌ្ឍជាច្រើនទៀតផងដែរ។

តាមប្រវត្តិសាស្ត្រប្រទេសកម្ពុជា មិនមានឯកសារណាមួយ ដែលបានបញ្ជាក់ច្បាស់លាស់អំពីដំណើរវិវត្តនៃវិស័យរៀបចំដែនដី និងនគរូបនីយកម្មទេ បើទោះជាកម្ពុជា បានឆ្លងកាត់នូវសម័យកាលដ៏រុងរឿងនៃរាជាណាចក្រអង្គរក៏ដោយ។ ការរៀបចំទីក្រុងរបស់ខ្មែរនាសម័យនោះគឺតាមបែបព្រហ្មញ្ញសាសនា និងព្រះពុទ្ធសាសនា រួមទាំងការរៀបចំទីក្រុង និងទីប្រជុំជនជននៅតាមខេត្តនានា។ តាមធម្មតា ប្លង់ទីក្រុងបែកចេញពីប្លង់ប្រាសាទដែលឋិតនៅចំកណ្តាល ហើយប្រាសាទទាំងនេះត្រូវហ៊ុំព័ទ្ធដោយកំពែងមួយជាន់ ឬពីរជាន់ ឯនៅខាងក្រៅកំពែងមានគូទឹកហ៊ុំព័ទ្ធមួយជាន់ទៀត។ ចំណែកឯ ទីប្រជុំជនឬបណ្តុំភូមិឋាននានា គឺមានផ្ទះកណ្តាលមួយ ហើយបន្តបន្ទាប់ដោយលំនៅឋានផ្សេងទៀតហ៊ុំព័ទ្ធជុំវិញ[4]។

តួនាទីការងារនៃវិស័យនគរូបនីយកម្មនៅកម្ពុជាក្រោយអាណានិគមបារាំង គឺស្ថិតនៅក្រោមចំណុះស្ថាប័នច្រើនដោយឡែកពីគ្នា។ ចាប់តាំងពីសម័យសង្គមរាស្ត្រនិយមរហូតមកដល់មុនឆ្នាំ ១៩៧៥ វិស័យរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ត្រូវបានគ្រប់គ្រងដោយនាយកដ្ឋាននគរូបនីយកម្មនិងលំនៅឋាន នៃក្រសួងសាធារណការ ហើយនៅតាមបណ្តាខេត្តក្រុងនានា កិច្ចការទាំងនេះ ត្រូវបានគ្រប់គ្រងដោយមន្ទីរសាធារណការនៃខេត្តក្រុងទាំងនោះ។

ក្រោយថ្ងៃរំដោះ ៧ មករា ១៩៧៩ បន្ទាប់ពីមានរៀបចំរចនាសម្ព័ន្ធរដ្ឋបាល ដោយរបបសាធារណរដ្ឋប្រជាមានិតកម្ពុជា មន្ទីររៀបចំក្រុងត្រូវបានបង្កើតនៅក្រុងភ្នំពេញ និងការិយាល័យសំណង់ ត្រូវបានបង្កើតនៅតាមបណ្តាខេត្តនានា ដោយនៅខេត្តខ្លះត្រូវដាក់ឱ្យស្ថិតនៅក្រោមមន្ទីរផែនការ និងនៅខេត្តខ្លះទៀត ការិយាល័យនេះស្ថិតនៅក្រោមមន្ទីរឧស្សាហកម្ម។ ទន្ទឹមនឹងនេះ សហគ្រាសសំណង់មួយ ក៏ត្រូវបានបង្កើតឡើងស្ថិតនៅក្រោមក្រសួងឧស្សាហកម្ម ដើម្បីសាងសង់សំណង់របស់រដ្ឋនៅទូទាំងប្រទេស លើកលែងសំណង់របស់ក្រសួងពាណិជ្ជកម្ម ដែលនាពេលនោះ មានក្រុមហ៊ុនមួយទទួលបន្ទុកសាងសង់។ នៅឆ្នាំ១៩៨៦ ដោយសារវិស័យសំណង់មានការរីកចម្រើន អគ្គនាយកដ្ឋានសំណង់ត្រូវបានបង្កើតឡើងស្ថិតនៅចំណុះក្រុមប្រឹក្សារដ្ឋមន្ត្រី ដើម្បីគ្រប់គ្រងវិស័យរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។ ឆ្នាំ១៩៩៣ រាជរដ្ឋាភិបាលនីតិកាលទី១នៃរដ្ឋសភា អគ្គនាយកដ្ឋាននេះ ស្ថិតនៅក្រោមក្រសួងសាធារណការ និងដឹកជញ្ជូន ជំនួសវិញ។ ឆ្នាំ១៩៩៤ ក្រោយមានច្បាប់ស្តីពីការរៀបចំទឹកដីនគរូបនីយកម្ម និងសំណង់ វិស័យរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ ត្រូវបានដឹកនាំនិង

[4] បណ្ឌិត អ៊ូ រ៉េឌី ប្រវត្តិនគរូបនីយកម្មនៅកម្ពុជា ទំព័រ១៧

គ្រប់គ្រងដោយគណៈកម្មាធិការជាតិរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់ ដែលមានទីស្នាក់ការនៅទីស្តីការគណៈរដ្ឋមន្ត្រី។

ដោយឡែក សម្រាប់វិស័យសុរិយោដី ដែលត្រូវបានបង្កើតនៅឆ្នាំ១៩០៨មានឈ្មោះថា ក្រុមសុរិយោដី និងឋានលេខា ស្ថិតនៅក្រោមទីស្តីការគណៈរដ្ឋមន្ត្រី ហើយនៅឆ្នាំ១៩២៥ ត្រូវបានបង្កើតនាយកដ្ឋានអភិរក្សភូមិបាល ស្ថិតនៅក្រោមក្រសួងហិរញ្ញវត្ថុ។ ឆ្នាំ១៩៤៨-១៩៧៥ ក្រុមសុរិយោដី និងការិយាល័យភូមិបាល ត្រូវបានបង្កើតឡើងស្ថិតនៅក្រោមក្រសួងកសិកម្ម។ ឆ្នាំ១៩៨៩-១៩៩៤ វិស័យនេះស្ថិតនៅក្រោមក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។ ចាប់ពីឆ្នាំ១៩៩៥ ដល់ឆ្នាំ១៩៩៩ គឺជានាយកដ្ឋានសុរិយោដី ដែលចំណុះទីស្តីការគណៈរដ្ឋមន្ត្រី។

ចំណែកឯ វិស័យភូមិសាស្ត្រវិញ ពីឆ្នាំ១៩៥៥ ស្ថិតនៅចំណុះក្រសួងការពារជាតិ មានឈ្មោះថា ក្រុមភូមិសាស្ត្រកម្ពុជា បន្ទាប់មកដូរឈ្មោះជាក្រុមភូមិសាស្ត្រខ្មែរ នៅក្រោមរបប លន់ នល់ និងពីឆ្នាំ១៩៨៥-១៩៩១ ជាការិយាល័យព្រំដែន ចំណុះក្រុមប្រឹក្សារដ្ឋមន្ត្រី និងពីឆ្នាំ១៩៩១ ដល់ចុងឆ្នាំ ១៩៩៨ ជានាយកដ្ឋានភូមិសាស្ត្រ ចំណុះទីស្តីការគណៈរដ្ឋមន្ត្រី។

ដោយមើលឃើញអំពីសារៈសំខាន់ និងចំណងទាក់ទងនៃវិស័យការងារខាងលើ ដែលចល័តនៅក្រោមចំណុះស្ថាប័នច្រើនដោយឡែកៗពីគ្នា ទើបរាជរដ្ឋាភិបាលកម្ពុជា បានសម្រេចបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ឡើង ដើម្បីទទួលបន្ទុកប្រមូលផ្តុំការងារទាំងអស់ខាងលើឱ្យមានស្ថេរភាព និងស្ថិតនៅក្រោមស្ថាប័នតែមួយ។ នៅពេលចាប់ផ្តើមដំណើរការក្រសួងដំបូង ទីស្តីការក្រសួងមានអគារធ្វើការនៅលើទីតាំងដីបីកន្លែងស្ថិតនៅឆ្ងាយពីគ្នាក្នុងខណ្ឌពីរផ្សេងគ្នា។ នៅឆ្នាំ១៩៩៩ រាជរដ្ឋាភិបាលបានអនុញ្ញាតឱ្យសាងសង់អគារថ្មីមួយខ្នងទៀតនៅក្នុងខណ្ឌចំការមន (មហាវិថីមុនីវង្ស) ដើម្បីដោះស្រាយកន្លែងធ្វើការជូនមន្ត្រីរាជការ ដែលមានកំណើនជាលំដាប់ស្របតាមសំណូមពរការងារកើនឡើង។ កំណើនការងាររៀបចំដែនដី និងនគរូបនីយកម្ម កាន់តែមានតម្រូវការច្រើនឡើងៗជាបន្តបន្ទាប់ រាជរដ្ឋាភិបាលបានផ្តល់លទ្ធភាពជាច្រើន រួមទាំងការបន្ថែមអគារ និងផ្លាស់ប្តូរទីតាំង ដើម្បីប្រសិទ្ធភាពការងារគ្រប់គ្រងដែនដីនគរូបនីយកម្ម និងសំណង់។ ពិសេសជាងនេះ គឺគម្រោងសាងសង់សំណង់នៃក្រសួងនេះត្រូវបានសិក្សាដោយស្ថាបត្យករ និងវិស្វករជាកូនខ្មែរ ហើយដំណើរការសាងសង់ក៏ស្ថិតនៅក្រោមការត្រួតពិនិត្យយ៉ាងម៉ត់ចត់ដោយអ្នកបច្ចេកទេសដែលជាកូនខ្មែរ និងជាមន្ត្រីរបស់ក្រសួងផងដែរ។

## ២- សមត្ថកិច្ចនគរូបនីយកម្មនៅកម្ពុជា

វិស័យនគរូបនីយកម្មនៅកម្ពុជា ស្ថិតក្រោមសមត្ថកិច្ចរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ដែលត្រូវបានបង្កើតឡើងនៅចុងឆ្នាំ១៩៩៨ តាមព្រះរាជក្រឹត្យលេខនស/រក

ត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨។ នៅក្នុងនីតិកាលទី២នៃរដ្ឋសភា(១៩៩៨-២០០៣) ច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ត្រូវបានចូលជាធរមាន តាមព្រះរាជក្រមលេខនស/រកម/០៦៩៩/០៩ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩[5]។ ក្រសួងនេះ មានបេសកកម្មដឹកនាំ និងគ្រប់គ្រងលើការងាររៀបចំដែនដី នគរូបនីយកម្ម សំណង់ សុរិយោដី និងភូមិសាស្ត្រនៃព្រះរាជាណាចក្រកម្ពុជា លើកលែងតែតំបន់ណា ឬសមត្ថកិច្ចណា ដែលរាជរដ្ឋាភិបាលប្រគល់ឱ្យស្ថាប័នផ្សេងទៀត។ តាមអនុក្រឹត្យនៃការរៀបចំ និងប្រព្រឹត្តិទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ បានបែងចែករចនាសម្ព័ន្ធ ដូចតទៅ[6]៖

## ២. ១- អង្គភាពថ្នាក់កណ្តាល(ជាតិ)

- ខុទ្ទកាល័យរដ្ឋមន្ត្រី
- អគ្គាធិការដ្ឋាន
- អគ្គនាយកដ្ឋានរដ្ឋបាល
- អគ្គនាយកដ្ឋានរៀបចំដែនដី និងនគរូបនីយកម្ម
- អគ្គនាយកដ្ឋានសំណង់
- អគ្គនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្រ
- អគ្គនាយកដ្ឋានលំនៅឋាន
- មន្ទីរពិសោធន៍ជាតិសំណង់
- មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈ
- គ្រឹះស្ថាន និងសហគ្រាសក្រោមឱវាទ
- អង្គភាពត្រួតពិនិត្យហិរញ្ញវត្ថុ

## ២.២- អង្គភាពមូលដ្ឋាន

អង្គភាពមូលដ្ឋាន គឺមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី ដែលមានទីតាំងនៅរាជធានី និងនៅតាមបណ្តាខេត្តនានា ហើយចំណុះទៅដោយការិយាល័យរៀបចំដែនដី សំណង់ និងភូមិបាល ដែលជាសេនាធិការនៅតាមខណ្ឌស្រុកក្រុងនីមួយៗ ទទួលបន្ទុកអនុវត្ត និងសម្របសម្រួល សកម្មភាពការងាររបស់មន្ទីរ ក៏ដូចជាការងាររបស់ក្រសួងដែរ។ ជាទូទៅការងាររៀបចំដែនដី និងនគរូបនីយកម្មនៅថ្នាក់មូលដ្ឋាន គឺសហការជាមួយអង្គភាពមូលដ្ឋាន ដើម្បីស្រាវជ្រាវប្រមូលឯកសារ ព័ត៌មាន និងចងក្រងទិន្នន័យប្រជាសាស្ត្រ និងសេដ្ឋកិច្ចសង្គម ដែលទាក់ទងនឹងការរៀបចំដែនដី និងនគរូបនីយកម្ម ដូចជា ចំនួនរបាយប្រជាជន ប្រភេទលំនៅដ្ឋាន ឬសំណង់ និងលក្ខណៈសង្គម(ជីវភាព សមត្ថភាពផ្គត់ផ្គង់និងដឹកជញ្ជូន) ជាដើម។ ជាងនេះទៀត អង្គភាពមូលដ្ឋាន គឺបានចូលរួមកសាងប្លង់គោលនៅតាមមូលដ្ឋាន និងចងក្រងឯកសារផែនការជាតិ ស្តីអំពីការរៀបចំដែនដីនិងការផ្តល់ព័ត៌មាន និងការកំណត់បែបផែននៃប្រភេទដី។ ម្យ៉ាងទៀត

[5] https://mlmupc.gov.kh/ministry-background សាវតាក្រសួង រ.ដ.ន.ស ចូលអាន ៤ កុម្ភៈ ២០២៤

[6] https://mlmupc.gov.kh រចនាសម្ព័ន្ធក្រសួង រ.ដ.ន.ស ចូលអាន ៤ កុម្ភៈ ២០២៤

មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និង សុរិយោដី មានតួនាទីផ្សព្វផ្សាយ បទបញ្ញត្តិនិង លិខិតបទដ្ឋាននានា ដែលទាក់ទងនឹងការរៀបចំដែនដី និងនគរូបនីយកម្ម ទៅដល់មូលដ្ឋាន និង តាមដានការអនុវត្តច្បាប់ បទបញ្ញត្តិការងាររៀបចំដែនដី និងនគរូបនីយកម្ម របស់អជ្ញាធរមូលដ្ឋាន ទៀតផង។

## ២.៣- សមត្ថកិច្ចអគ្គនាយកដ្ឋាន រៀបចំដែនដី និងនគរូបនីយកម្ម

អគ្គនាយកដ្ឋានរៀបចំដែនដី និងនគរូបនីយកម្ម ជាអង្គភាពជំនាញចំណុះក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ មានភារកិច្ចជាសេនាធិការឱ្យក្រសួងក្នុងការងារលើកសំណើ និង អនុវត្តនយោបាយយុទ្ធសាស្ត្រ រៀបចំដែនដី និង នគរូបនីយកម្ម ដើម្បីអភិវឌ្ឍសេដ្ឋកិច្ច និងសង្គម ប្រកបដោយតុល្យភាព ចីរភាព សំដៅការពារផលប្រយោជន៍ទូទៅ និងរៀបចំចងក្រងព័ត៌មាន ទិន្នន័យ ដោយសហការជាមួយក្រសួងស្ថាប័នពាក់ព័ន្ធនានា ដើម្បីធ្វើការសិក្សា វិភាគសម្រាប់អនាគត។ ជាមួយគ្នានេះដែរ អគ្គនាយកដ្ឋាននេះ មានតួនាទីរៀបចំគោលនយោបាយ ផែនការ កម្មវិធី នីតិវិធីច្បាប់ បទប្បញ្ញត្តិ លិខិតបទដ្ឋាន ស្តង់ដារ និងវិធានការ ដែលទាក់ទងនឹងការរៀបចំដែនដី និងនគរូបនីយកម្ម។ អគ្គនាយកដ្ឋាននេះ ដឹកនាំដោយអគ្គនាយកមួយរូប អមដោយអគ្គនាយករង ទទួលបន្ទុកតាមជំនាញ។ អគ្គនាយកដ្ឋាន មាននាយកដ្ឋានជំនាញចំណុះចំនួនបី ដូចខាងក្រោម[7]៖

- នាយកដ្ឋានស្រាវជ្រាវ និង បទប្បញ្ញត្តិ
- នាយកដ្ឋានរៀបចំដែនដី
- នាយកដ្ឋាននគរូបនីយកម្ម



រូបភាព៖ អគារទីស្តីការក្រសួង រ.ដ.ន.ស.
ប្រភព៖ គេហទំព័រ ក្រសួង រ.ដ.ន.ស.

## ៣- ស្ថានភាពនគរូបនីយកម្មនៅកម្ពុជា

ស្ថានភាពនៃនគរូបនីយកម្មនិងការអភិវឌ្ឍទីក្រុងនៅប្រទេសកម្ពុជា ក៏មិនសូវខុសគ្នាទៅនឹងការអភិវឌ្ឍទីក្រុងនៃប្រទេសនានាក្នុងតំបន់ដែរ។ ភ្នំពេញ គឺជារាជធានីនៃព្រះរាជាណាចក្រកម្ពុជា កំពុងមានការរីកចម្រើនយ៉ាងឆាប់រហ័ស ប៉ុន្តែងាយរងគ្រោះ ទាំងផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ និងភាពក្រីក្រនៅក្នុងសហគមន៍នានានៃទីក្រុង។ ការធ្វើផែនការរៀបចំដែនដី និងការកំណត់ការប្រើប្រាស់ដី គឺជាទស្សនទាននៃការអនុវត្ត និងគ្រប់គ្រងវិស័យនគរូបនីយកម្មនៅកម្ពុជា។ រលកនៃការធ្វើនគរូបនីយកម្ម នាពេលបច្ចុប្បន្នកំពុងកើតឡើងជាបន្តបន្ទាប់ ស្របពេលជាមួយនឹងការផ្លាស់ប្តូរនីតិវិធីរបស់រាជរដ្ឋាភិបាល

[7] https://mlmupc.gov.kh ចូលអាន ៤ កុម្ភៈ ២០២៤

ដើម្បីចាត់ថ្នាក់លំហអេកូឡូស៊ីសង្គម និងមុខងារនៃតំបន់នីមួយៗរបស់ទីក្រុងឬទីប្រជុំជន។ ជាមួយគ្នានេះដែរ ការពង្រីកនិងរៀបចំគ្រប់គ្រងទីក្រុងដោយសិក្សាអំពីធនធានមូលដ្ឋាន គឺជាយន្តការដែលមិនត្រូវមើលរំលង សម្រាប់លទ្ធភាពដែលមានផលប៉ះពាល់កម្រិតអតិប្បរមា។

នៅពេលដែលប្រទេស កាន់តែមានការវិវត្តភាពស្មុគ្រស្មាញកាន់តែកើនឡើង ដែលតម្រូវឱ្យមានវិធានការកាន់តែច្រើន ដើម្បីធ្វើឱ្យផលប៉ះពាល់កាន់តែតិច។ វិស័យរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ នៅប្រទេសកម្ពុជា មានការអភិវឌ្ឍគួរឱ្យកត់សម្គាល់ ប្រមាណជាងពីរទសវត្សរ៍ចុងក្រោយនេះ ក្រោយមានការចិត្តទុកដាក់ខ្ពស់ពីរាជរដ្ឋាភិបាល ជាពិសេសលើការងារលំនៅឋានសម្បទានដីសង្គមកិច្ច តាមរយៈការអភិវឌ្ឍលំនៅឋានដីសង្គមកិច្ច ប្រកបដោយចីរភាព។ ជាមួយគ្នានេះដែរ ផលិតកម្មកសិកម្ម ប្រព័ន្ធគាំពារសង្គមកិច្ច សេវាអប់រំនិងសុខាភិបាល ព្រមទាំងសេវាសង្គមកិច្ចនានា ដែលអាចទ្រទ្រង់ការអភិវឌ្ឍសហគមន៍ ពិសេសនិរន្តរភាពជីវភាព និងសេដ្ឋកិច្ចគ្រួសារ ក៏ត្រូវបានយកចិត្តទុកដាក់ផងដែរ។

កំណើនប្រជាជន និងតម្រូវការលំនៅឋានចេះតែកើនឡើងជាលំដាប់ នៅក្នុងប្រទេសកម្ពុជា គឺទាមទារឱ្យមានការចិត្តទុកដាក់ខ្ពស់អំពីរាជរដ្ឋាភិបាល ពោលគឺការគិតគូរយកចិត្តទុកដាក់លើបញ្ហាទាំងនេះ ដើម្បីបញ្ចៀសការធ្វើចំណាកជនបទ ចូលមកកាន់កាប់បណ្តោះអាសន្នលើដីរដ្ឋដីឯកជន និងបង្កើតជាតំបន់អនាធិបតេយ្យ។ នៅតាមទីក្រុងនិងទីប្រជុំនានា បញ្ហាកាន់កាប់ដីរដ្ឋបានកើតមាននិងបានបង្កើតជាបញ្ហាលំបាកដែលរាជរដ្ឋាភិបាល បាននិងកំពុងធ្វើការដោះស្រាយ ជាពិសេសរាជធានីភ្នំពេញ។ បន្ទាប់ពីមានសុខសន្តិភាពពេញបរិបូរណ៍ទូទាំងកម្ពុជា រាជធានីភ្នំពេញ ក៏ដូចជាទីប្រជុំជនផ្សេងទៀតដែរ បានក្លាយជាចំណុចស្រូបទាញ យកអ្នកចំណាកពីទីជនបទចូលមករស់នៅ ដែលភាគច្រើនបំផុតគឺដើម្បីជីវភាពប្រសើរឡើង។ ជាក់ស្តែង ដីធ្លីដែលនៅទំនេរពីមុន បានក្លាយទៅជាសំណង់លំនៅឋានប្រភេទផ្សេងៗ ដូចជា ភូមិគ្រឹះ ផ្ទះល្វែង តំបន់ជាបុរី ដែលធ្វើឱ្យរាជធានីភ្នំពេញពង្រីកខ្លួនយ៉ាងលឿន ជាពិសេសតាមតំបន់ជាយក្រុង។



*រូបភាព៖ សង្កាត់ចតុមុខរាជធានីភ្នំពេញឆ្នាំ២០១៩*
*ប្រភព៖ វេទិកានគរូបនីយកម្មលើកទី១*

## ៤- នគរូបនីយកម្មនិងបញ្ហាប្រឈម

ប្រមាណ ជាងពីរទសវត្សរ៍ចុងក្រោយនេះ វិស័យនគរូបនីយកម្មនិងការអភិវឌ្ឍទីក្រុង ឬទីប្រជុំជន និងកំណើនប្រជាជន ក្នុងប្រទេសកម្ពុជា មានការកើនឡើងគួរឱ្យកត់សម្គាល់។ ប្រជាជនប្រមាណជា ៧៦% ដែលកំពុងរស់នៅជនបទ ភាគច្រើននៃប្រជាជនទាំងនោះ ត្រូវបានផ្តោតការយកចិត្តទុកដាក់ លើទម្រង់ការងារអភិវឌ្ឍន៍ជាច្រើន ដើម្បីកាត់បន្ថយភាពក្រីក្រ។ ដោយសារស្ថានភាពអត្រានគរូបនីយកម្ម នៅក្នុងប្រទេសកម្ពុជាមានល្បឿនលឿន និងទំនាក់ទំនងមិនអាចប្រកែកបាន រវាងបរិស្ថានជនបទនិងទីក្រុង ដែលជាលទ្ធផលនៃការធ្វើចំណាកជនបទ មកទីក្រុងឬទីប្រជុំជននៅក្នុងប្រទេស។ ការណ៍នេះ ជំរុញឱ្យមានកំណើនតម្រូវការនានា ដើម្បីរៀបចំដែនដីក្នុងទីក្រុង (លំនៅឋាននិងទីលំហ) ដែលភាគច្រើនត្រូវបានផ្លាស់ប្តូរទៅតាមបរិបទសង្គម និងសេដ្ឋកិច្ច ខណៈពេលនៃកំណើនយ៉ាងឆាប់រហ័សកំពុងកើតមាននៅក្នុងប្រទេស។

លំហទីក្រុងនៃប្រទេសកម្ពុជា គឺជាទីកន្លែងនៃស្ថានភាពត្រួតស៊ីគ្នារវាងភាពក្រីក្រ និងកាលានុវត្តភាព ជាមួយនឹងឧបសគ្គនៃការធ្វើនគរូបនីយកម្មឆាប់រហ័ស ព្រមជាមួយនឹងដំណើរការនៃការផ្លាស់ប្តូបរិស្ថានតំបន់ និងសាកលលោកសង្គមនិងសេដ្ឋកិច្ច។ ទីក្រុង គឺជាលំហស្មុគស្មាញ ដែលមានកម្លាំងទន្ទឹមគ្នាច្រើនអនេក និងកម្រិតផ្សេងគ្នានៃសង្គម នយោបាយ បរិស្ថាន និងសេដ្ឋកិច្ច។ ការកើនឡើងនូវតម្រូវការក្នុងស្រុកសម្រាប់លំនៅឋាន ក្នុងចំណោមក្រុមមនុស្សដែលមានកម្រិតសេដ្ឋកិច្ចសង្គមពីមធ្យមទៅខ្ពស់ បានធ្វើឱ្យមានការកើនឡើងយ៉ាងឆាប់រហ័ស នៃការអភិវឌ្ឍ អចលនទ្រព្យ។ ព្រឹត្តិការណ៍ទាំងនេះ បានជំរុញឱ្យមានការសាងសង់លំនៅឋានជាច្រើន ដើម្បីឆ្លើយតបទៅនឹងតម្រូវការនៃកំណើនទាំងនោះ។ បន្ថែមលើនេះទៀត ការអនុម័តច្បាប់ថ្មីនៅក្នុងឆ្នាំ២០១០ ដែលមានការផ្តល់សិទ្ធកម្មសិទ្ធិ លើចំណែកឯកជននៃអគារសហកម្មសិទ្ធិដល់ជន

បរទេសចាប់ពីជាន់ទី១ឡើងទៅ បានបង្កើនវិនិយោគទុនដោយប្រថុយប្រថាន និងការកើនឡើងយ៉ាងឆាប់រហ័សនៃតម្លៃលំនៅឋាននិងដីធ្លី។

បើទោះបីជាកំណើនមនុស្ស និងលំនៅឋាននៅទីក្រុងនិងទីប្រជុំជន តាមរយៈការធ្វើចំណាកជនបទ បានបង្ហាញនូវចំណុចវិជ្ជមានមួយចំនួននៅក្នុងសង្គម ដូចជាការផ្លាស់ប្តូរទស្សនៈពឹងផ្អែកធម្មជាតិនៃផលិតកម្មកសិកម្មនៅជនបទ រួមទាំងការអភិវឌ្ឍជាច្រើននានានៃទីក្រុងក៏ដោយ ក៏ប៉ុន្តែកំណើនទាំងនេះ បានធ្វើឱ្យទីក្រុងនិងទីប្រជុំជនមានចំណុចអវិជ្ជមានមួយចំនួន ដូចជា៖

- ផលប៉ះពាល់ផ្នែកសេដ្ឋកិច្ច៖ នៅពេលទីក្រុងមានការរីកចម្រើន ផលប៉ះពាល់ជាច្រើននឹងកើតមានឡើង រួមបញ្ចូលទាំងការកើនឡើងយ៉ាងខ្លាំង និងការប្រែប្រួលថ្លៃដើមរបស់ទំនិញនានា នៅក្នុងទីផ្សារផងដែរ ដោយសារនិន្នាការនគរូបនីយកម្មយ៉ាងឆាប់រហ័ស។
- ផលប៉ះពាល់ផ្នែកបរិស្ថាន៖ ទីក្រុងនិងទីប្រជុំជននានា បានក្លាយទៅជាកន្លែងរួមនៃការកើនឡើងនៃកម្តៅ តាមរយៈកំណើនផលិតកម្ម ដែលអាចនឹងមានឥទ្ធិពល ទៅលើចំណុចមូលដ្ឋានផ្សេងទៀត ដូចខាងក្រោម ៖
    - គុណភាពទឹក
    - កាកសំណល់ចំណីអាហារ
    - ទីជម្រកនិងជីវៈចម្រុះ ជាដើម។
- សុខុមាលភាពសង្គម៖ ការធ្វើនគរូបនីយកម្មយ៉ាងឆាប់រហ័ស បាននាំឱ្យមានការកើនឡើងនូវអត្រាស្លាប់ខ្ពស់ ដោយសារជំងឺធ្ងន់ ទាក់ទងទៅនឹងរបៀបរបបនៃការរស់នៅ ហើយអត្រាមរណៈភាពនៅក្នុងទីក្រុង អាចប្រែប្រួលអាស្រ័យលើ ៖
    - អាហារូបត្ថម្ភ
    - ជំងឺធ្ងន់
    - ឧក្រិដ្ឋកម្ម
    - សុខភាពផ្លូវចិត្ត

## សេចក្តីសន្និដ្ឋាន

ជាទូទៅ វិស័យនគរូបនីយកម្មនៅក្នុងប្រទេសកម្ពុជា បានរីកចម្រើនជាបន្តបន្ទាប់ តាមរយៈការបង្កើនការប្រមូលផ្តុំនៃសកម្មភាពនានារបស់មនុស្ស និងការតាំងទីលំនៅក្នុងទីក្រុងនិងទីប្រជុំជននានា ដែលសកម្មភាពនិងការតាំងទីលំនៅទាំងនោះ បានមកពីការធ្វើចំណាកទីជនបទរបស់ប្រជាជន។ ជាមួយគ្នានេះ គឺតម្រូវ ឱ្យមានការគ្រប់គ្រង ការប្រើប្រាស់និងការបែងចែកដីធ្លី ការគ្រប់គ្រងនិងការប្រើប្រាស់ធនធានធម្មជាតិ និងហេដ្ឋារចនាសម្ព័ន្ធរូបវន្តនិងសង្គម ប្រកបដោយការទទួលខុសត្រូវច្បាស់លាស់ ស្របទៅតាមឋានានុក្រមនៃការរៀបចំដែនដី នគរូបនីយកម្មដោយឈរលើមូលដ្ឋាននៃការចូលរួម និងកិច្ចសហការជិតស្និតពីគ្រប់ភាគីពាក់ព័ន្ធ ស្របតាមក្របខណ្ឌគតិយុត្ត និងការអនុវត្តប្រកបដោយ

ភាពជោគជ័យ។ កំណើនជាប្រចាំចំនួនប្រជាជន និងការប្រែប្រួលផ្នែកសេដ្ឋកិច្ច និងវប្បធម៌ នៅក្នុងបរិបទនៃសាកលភាវូបនីយកម្ម គឺទាមទារចាំបាច់នូវប្រសិទ្ធភាព និងនិរន្តរភាពនៃការរៀបចំដែនដី និងនគរូបនីយកម្ម។ ទម្រង់ផ្សេងគ្នានៃនគរូបនីយកម្ម អាចត្រូវបានចាត់ថ្នាក់ដោយឡែក អាស្រ័យលើរចនាបថនិងវិធីសាស្ត្រនៃស្ថាបត្យកម្មក្នុងការធ្វើផែនការ ក៏ដូចជា ការរៀបរយកំណើនប្រជាជនជាប្រវត្តិសាស្ត្រនៃតំបន់នោះ។ ការរីកចម្រើនជាបន្តបន្ទាប់ តាមរយៈការកែលម្អទីក្រុង និងទីប្រជុំជនជាដើម គឺជាការមកដល់ថ្មីៗនៃភាពស៊ីវិល័យរបស់ទីក្រុង និងទីប្រជុំជនទាំងនោះ ដែលលែងត្រូវការសំណង់ឬលំនៅឋានមិនរៀបរយ ព្រោះនៅក្នុងតំបន់អភិវឌ្ឍន៍មួយចំនួននៃទីក្រុង ឬទីប្រជុំជន ត្រូវបានត្រៀមលក្ខណៈជាស្រេចនៅក្នុងផែនការនគរូបនីយកម្មនៃតំបន់ទីប្រជុំជននោះ។ ទម្រង់នៃការធ្វើនគរូបនីយកម្មទាំងនេះ អាចកើតមានដោយសារទំនាក់ទំនងប្រសើរឡើង រវាងប្រជាជនទីក្រុង និងជនបទ ប៉ុន្តែកត្តាមួយចំនួនដូចជា ការភ័យខ្លាចលើផ្នែកឧក្រិដ្ឋកម្ម និងការបំពុលបរិស្ថាន បានរួមចំណែកទៅដល់បាតុភាពនានា ដែលធ្វើឱ្យទីក្រុងនិងទីប្រជុំជនធ្លាក់ចុះ រួមទាំងគុណភាពការរស់នៅ និងសោភណ្ឌភាពទីក្រុង និងទីប្រជុំជនទាំងនោះ។

ជារួម ខណៈពេលដែលវិស័យនគរូបនីយកម្មនៅកម្ពុជាកំពុងកើនឡើង ក្នុងសំទុះមួយដ៏គួរឱ្យកត់សម្គាល់និងឆាប់រហ័ស បញ្ហាប្រឈមដែលមិនអាចចៀសរួចក៏កើតមានទន្ទឹមគ្នាផងដែរនៅក្នុងទីក្រុងនិងទីប្រជុំជន ដូចជា ការកកស្ទះចរាចរណ៍ ការបំពុលបរិស្ថាន កង្វះហេដ្ឋារចនាសម្ព័ន្ធ កង្វះបណ្តាញទឹកស្អាតនិងអគ្គិសនី បញ្ហាសំរាមសំណង់និងលំនៅឋានអនាធិបតេយ្យ បញ្ហាអសន្តិសុខនិងឧក្រិដ្ឋកម្ម និងកង្វះអនាម័យ ជាដើម។ ការរៀបចំផែនការគ្រប់គ្រងទីក្រុងឱ្យកាន់តែល្អប្រសើរ អាចរួមចំណែកដោះស្រាយបញ្ហាទាំងនេះ តាមរយៈការធ្វើយ៉ាងណាឱ្យការអភិវឌ្ឍទីក្រុងនាពេលអនាគត កាន់តែមានចីរភាព ការផ្តល់ឱកាស និងអត្ថប្រយោជន៍កាន់តែប្រសើរដល់ប្រជាជន ពោលគឺការផ្តោតការយកចិត្តទុកដាក់លើតម្រូវការ និងការចូលរួមរបស់ប្រជាជន។ ការគ្រប់គ្រងនៃវឌ្ឍនភាពវិស័យនគរូបនីយកម្ម ត្រូវតែផ្តោតការយកចិត្តទុកដាក់ក្នុងការ កសាងភាពជាដៃគូ រវាងរាជរដ្ឋាភិបាល វិស័យឯកជន និងសង្គមស៊ីវិល សំដៅរួមចំណែកដល់ការបង្កើនប្រសិទ្ធភាព ភាពប្រកួតប្រជែងផ្នែកសេដ្ឋកិច្ច និងអភិបាលកិច្ច ប្រកបដោយបរិយាបន្នក្នុងទីក្រុង និងទីប្រជុំជននានាទូទាំងប្រទេស រួមទាំងសុខុមាលភាពរបស់ប្រជាជនផងដែរ។

## **គន្ថនិទ្ទេស**


- *ហៃ សុគន្ធា "នគរូបនីយកម្មសាកលលោកនិងចំណាកជនបទ" អត្ថបទស្រាវជ្រាវ ២០១៩*
- *ក្រុមប្រឹក្សាជាតិភាសាខ្មែរ: សទ្ទានុក្រម ភូមិវិទ្យា និងប្រវត្តិវិទ្យា ឆ្នាំ២០១៨*
- *បណ្ឌិតសភាចារ្យ ឆយ អូន "បម្លាស់លំនៅនៃប្រជាជនកម្ពុជាឆ្លងកាត់របបផ្សេងៗ" ឆ្នាំ២០១៧*
- *ក្រសួងផែនការ: ជំរឿនទូទៅនៃប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១៩ វិទ្យាស្ថានជាតិស្ថិតិ ឆ្នាំ២០២០*
- *បណ្ឌិត អ៊ូ វ៉ឌី "ប្រវត្តិនគរូបនីយកម្មលើពិភពលោក" ភ្នំពេញ ឆ្នាំ២០១២*
- *បណ្ឌិត បេងហុង សុជាតិ ខេមរ៉ូ "ការកសាងរៀបចំដែនដីក្នុងទីក្រុង និង ទីប្រជុំជន" អត្ថបទសិក្ខាសាលាថ្នាក់ជាតិ ស្តីពី "ការរៀបចំដែនដី និង ទីក្រុង" ឆ្នាំ២០១១*
- *បណ្ឌិត បេងហុង សុជាតិ ខេមរ៉ូ "ទំនោរនៃការវិវត្តន៍និងអភិវឌ្ឍន៍របស់ទីក្រុងនៅក្នុងព្រះរាជាណាចក្រកម្ពុជា" ឆ្នាំ២០០៩*
- *វេទិកាពិភាក្សាស្តីពីភាពក្រីក្រនៅក្នុងទីក្រុង*
- Adam Saltsman, *ប៉ក់ គឹមជឿន "ដែនកំណត់នៃកំណើន៖ វិធីសាស្ត្រគ្រប់គ្រងភាពងាយរងគ្រោះក្នុងការស្វែងយល់អំពីនគរូបនីយកម្មនៅកម្ពុជា" ភ្នំពេញ ៤៨ ទំព័រ*
- *របាយការណ៍ វេទិកានគរូបនីយកម្មកម្ពុជា វិច្ឆិកា ឆ្នាំ២០១៩ ភ្នំពេញ ៤៧ ទំព័រ*
- https://mlmupc.gov.kh/ *ចូលអាន ថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០២៤*